# **ផ្លូវនៃអតីតកាលដើម្បីប្រឈមមុខនឹងអនាគត**

អែលឌើរ អិល ថម ភែរី
ក្រុមនៃពួកសាវកដប់ពីរនាក់

*មេរៀននៃអតីតកាល...រៀបចំខ្លួនយើងសំរាប់ការប្រឈមមុខនឹង ឧបសគ្គនាពេលអនាគត ។*

នៅរដូវក្ដៅឆ្នាំនេះ ភរិយារបស់ខ្ញុំ ហើយនឹងរូបខ្ញុំបានមានឱកាសចូលរួមក្នុងកម្មវិធីដង្ហែរក្បួនស្ដីអំពីអព្ភូតហេតុរបស់ពួកមរមន នៅទីក្រុងមែនធៃ រដ្ឋ យូថាហ៍ ។ នាយប់មួយ ពីមុនចាប់ផ្ដើមដង្ហែរក្បួននោះ យើងបាននិយាយទៅកាន់សមាជិកទាំងឡាយក្នុងក្រុមសម្ដែងនោះ ។ ដោយសារសមាជិកនៃក្រុមសម្ដែងនោះមានចំនួនច្រើនលើសលុប នោះយើងត្រូវនិយាយទៅកាន់ពួកគេជាពីរវគ្គ ។ ក្បួនដង្ហែរនោះមានមនុស្សជាង 800 នាក់ ដោយមានពួកគេចំនួន 570 នាក់មានអាយុក្រោម 18 ឆ្នាំ ។ មានសមាជិកនៃក្រុមសម្ដែងចំនួនមួយរយនាក់បន្ថែមទៀតបានចូលរួមនៅក្នុងឆ្នាំនេះ ដោយតំរូវឱ្យបងប្អូនស្រី ដែលគ្រប់គ្រងផ្នែកសំលៀកបំពាក់ត្រូវដេរសំលៀកបំពាក់បន្ថែមទៀត---ដែលពួកគាត់បានធ្វើពិតមែន ។ វាគឺជាការបំផុសគំនិតមួយ នៅពេលបានឃើញពីការរៀបចំដែលពួកគេធ្វើបានយ៉ាងល្អនោះ ។

ការរៀបចំនៃការដង្ហែរក្បួននោះ គឺត្រូវបានប្រារព្ធធ្វើឡើងនៅលើជាយភ្នំដ៏ស្រស់បំព្រងមួយដោយនៅខាងក្រោមព្រះវិហារបរិសុទ្ធមែនធៃបន្តិច ។ នៅរាត្រីដែលយើងទស្សនាការហែក្បួននោះ គឺមានមនុស្សចំនួន 15,000 នាក់បាន ចូលរួម ។ វាគឺជារឿងដ៏រំភើបមួយ ដោយមើលឃើញក្រុមយុវជនយុវនារីដ៏ធំនេះបានទទួលនូវការយល់ដឹងមួយអំពីដំណើររឿងនៃការស្ដារឡើងវិញ នៅពេលពួកគេសម្ដែងផ្នែករបស់ខ្លួនដោយភាពក្លៀវក្លា និងអង់អាចបែបនេះ ។

រឿងមួយដែលយើងចូលចិត្តធ្វើនៅពេលយើងទៅទស្សនាទីក្រុងមែនធៃនោះ គឺការចូលរួមប្រជុំនៅក្នុងព្រះវិហារបរិសុទ្ធ ។ នៅក្នុងព្រះវិហារបរិសុទ្ធដ៏ចំណាស់ទាំងនេះ ដែលត្រូវបានសាងសង់ឡើងមកពី ការលះបង់ដ៏ធំធេងពីសំណាក់ពួកអ្នកត្រួសត្រាយផ្លូវកាលពីសម័យមុន គឺមានវិញ្ញាណដ៏ពិសេសមួយ ។

ការចូលរួមប្រជុំមួយនៅក្នុងព្រះវិហារបរិសុទ្ធមែនធៃ គឺជាបទពិសោធន៍ដ៏រំជួលចិត្តមួយសំរាប់ខ្ញុំ ។ ខ្ញុំបាននឹកឃើញពីព្រះវិហារបរិសុទ្ធឡូហ្គិន ពីមុនព្រះវិហារបរិសុទ្ធនេះត្រូវគេតុបតែងជាថ្មីឡើងវិញ និងធ្វើឱ្យមានលក្ខណៈទំនើបនោះ ។ នៅពេលយើងឆ្លងដំណាក់កាលនិមួយៗនៃការប្រជុំក្នុងព្រះវិហារបរិសុទ្ធ នៅគ្រប់បន្ទប់ទាំងអស់ខ្ញុំបានស្ដាប់ឮ ពួកអ្នកត្រួសត្រាយកាលពីសម័យមុនបាននិយាយថា ៖ "ចូរសម្លឹងមើលអ្វីដែលយើងបានកសាងដោយដៃទាំងពីររបស់យើងចុះ ។ យើងគ្មានឧបករណ៍ទំនើប គ្មានអ្នកផ្គត់ផ្គង់ ឬអ្នកផ្គត់ផ្គង់ជំនួសដែលបានចូលប្រឡូកនៅក្នុងការសាងសង់នេះទេ ។ គ្មានប្រដាប់ស្ទូចទំនើប ដើម្បីលើកដុំថ្មធំៗឡើងឡើយ ។ យើងបានធ្វើកិច្ចការនេះដោយប្រើកម្លាំងរបស់យើងផ្ទាល់" ។

ឱ! កេរដំណែលដែលពួកអ្នកត្រួសត្រាយផ្លូវនៅក្រុងសាន់ប៉េតេ កាលពីសម័យមុន បានបន្សល់ទុកឱ្យយើងមានតម្លៃអ្វីម្ល៉េះទេ ។

អតីតប្រធានាធិបតីសហរដ្ឋអាមេរិកលោក រ៉ូណាល់ រីហ្គិនបានលើកឡើងនូវពាក្យដកស្រង់មួយថា ៖ "ខ្ញុំមិនចង់វិលត្រឡប់ទៅរករឿងដែលបានកើតមាននៅអតីតកាលនោះទេ។ ប៉ុន្តែ ខ្ញុំចង់ត្រឡប់ទៅរករបៀបនៃអតីតកាល ដើម្បីប្រឈមមុខនឹងអនាគតកាលវិញ"។1 ពាក្យទូន្មានប្រកបដោយប្រាជ្ញាញាណរបស់លោក បានដក់ជាប់នៅក្នុងដួងចិត្តរបស់ខ្ញុំជានិច្ច។ ចំពោះការមើលឡើងវិញនូវមេរៀននៃអតីតកាល ដើម្បីរៀបចំខ្លួនយើងសំរាប់ការប្រឈមមុខនឹងឧបសគ្គនាពេលអនាគតនោះ គឺមាននូវរឿងដ៏សំខាន់មួយនៅក្នុងនោះ។ ឱ! កេរមតកនៃសេចក្ដីជំនឿ សេចក្ដីក្លាហាន និងភាពប៉ិនប្រសប់ ដែលពួកអ្នកត្រួសត្រាយផ្លូវមរមនកាលពីសម័យមុន បានបន្សល់ទុកឱ្យយើងស្ថាបនាបន្ថែមទៀតនោះ មានភាពរុងរឿងអ្វីម្ល៉េះទេ។ នៅពេលរស់នៅកាន់តែយូរ នោះខ្ញុំមានការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះពួកគាត់។

ការឱបក្រសោបនឹងដំណឹងល្អបានធ្វើឱ្យជីវិតរបស់ពួកគេផ្លាស់ប្ដូរទាំងស្រុង។ ពួកគេលះបង់ចោលនូវអ្វីៗគ្រប់យ៉ាង---រួមមានផ្ទះសម្បែង ជំនួញ កសិដ្ឋាន ព្រមទាំងសមាជិកគ្រួសារជាទីស្រឡាញ់របស់ពួកគេផងដែរ---ហើយបានធ្វើដំណើរ ចូលទៅក្នុងទីរហោស្ថាន។ នៅពេលលោកព្រិក ហាំយ៉ង់ បានប្រកាសថា "នេះគឺជា...ទីកន្លែងនោះហើយ" វាប្រហែលជារឿងដ៏រន្ធត់ចិត្តមួយសំរាប់ពួកគេ។2 នៅពីមុខពួកគេសុទ្ធតែវាលខ្សាច់ដ៏ធំល្វឹងល្វើយ ដោយគ្មានភ្នំ ព្រៃប្រឹក្សា និងវាលស្មៅខៀវខ្ចីដ៏ស្រស់បំព្រងដែលអ្នកត្រួសត្រាយផ្លូវកាលពីសម័យមុនភាគច្រើនបានស្គាល់។ ដោយមានសេចក្ដីជំនឿរឹងមាំទៅលើព្រះ និងពួកអ្នកដឹកនាំរបស់ខ្លួន នោះពួកអ្នកត្រួសត្រាយផ្លូវសម័យមុន បានចេញទៅធ្វើការ ដើម្បីបង្កើតសហគមន៍ដ៏ស្រស់បំព្រងនៅក្បែរភ្នំទាំងឡាយ។

មានពួកអ្នកត្រួសត្រាយដ៏កំសត់ជាច្រើន ទើបតែចាប់ផ្ដើមរីករាយនឹងជីវិតសុខស្រួលដ៏សមរម្យ ជាពេលដែលលោកព្រិក ហាំយ៉ង់ បានអំពាវនាវសុំឱ្យពួកគេចាកចេញពីផ្ទះសម្បែងរបស់ខ្លួនជាថ្មីម្ដងទៀត ហើយធ្វើដំណើរទៅកាន់ ទិសខាងកើត ខាងលិច ខាងជើង និងខាងត្បូង ដើម្បីតាំងទីលំនៅតំបន់ព្រំប្រទល់រវាងរដ្ឋយូថាហ៍ និងរដ្ឋណេវ៉ាដា។ នេះគឺជារបៀបដែលសហគមន៍នៃក្រុងសាន់ប៉េតេ---រួមមានទីក្រុងហ្វៃវីយូ អ៊ីហ្វ្រែម មែនថៃ និងម៉ោនភ្លីសិន---ត្រូវបានស្ថាបនាឡើង។

នៅពេលខ្ញុំត្រឡប់ពីការទស្សនាក្រុងសាន់ប៉េតេវិញ នោះខ្ញុំបានមានបំណងប្រាថ្នាចង់រៀនសូត្របន្ថែមទៀតអំពីពួកអ្នកត្រួសត្រាយផ្លូវនៅទីនោះកាលពីសម័យមុន។ ខ្ញុំបានសំរេចចិត្តចំណាយពេលពីរទៅបីម៉ោង នៅក្នុងបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រថ្មី ហើយអានបន្តិចម្ដងៗពីប្រវត្តិរបស់ពួកគេ។

គឺនៅឆ្នាំ 1849 បន្ទាប់ពីពួកគេបានមកដល់ជ្រលងភ្នំសលត៍ លេក ជាពេលដែលលោកព្រិក ហាំយ៉ង់ ជាអ្នកត្រួសត្រាយដ៏អស្ចារ្យនៃភាគខាងលិច បានអំពាវនាវឱ្យពួកបរិសុទ្ធមួយក្រុម ដើម្បីធ្វើដំណើរទៅទិសខាងត្បូង ហើយចាប់ផ្ដើមសាងសង់ផ្ទះសម្បែង និងសហគមន៍របស់ពួកគេជាថ្មីម្ដងទៀត នៅលើវាលរហោស្ថានផ្សេងទៀត។ មិនយូរប៉ុន្មាន បន្ទាប់ពីពួកគេបានតាំងលំនៅក្នុងទីក្រុងសាន់ប៉េតេ ប្រធាន ហ៊ីប៊ើរ ស៊ី ឃិមប៊ល ជាទីប្រឹក្សារបស់ប្រធានព្រិក ហាំយ៉ង់ បានមកទស្សនកិច្ចសហគមន៍មែនថៃ ហើយបានសន្យានឹងពួកគេថា នៅលើកូនភ្នំដែលអាចមើលឃើញជ្រលងភ្នំនេះ នឹងមានព្រះវិហារបរិសុទ្ធមួយត្រូវបានសាងសង់ឡើងដោយប្រើថ្មភ្នំចាប់ពីភាគខាងកើតនៅក្នុង ការកសាងព្រះវិហារបរិសុទ្ធនេះ។

ជាច្រើនឆ្នាំបានកន្លងផុតទៅ បន្ទាប់ពីទស្សនកិច្ចរបស់ប្រធាន យិមប៊ីល ហើយប្រជាពលរដ្ឋទាំងឡាយបានចាប់ផ្តើមមានការព្រួយបារម្ភ ដោយសារគ្មានអ្វីបានកើតឡើងសោះ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធមួយសំរាប់ពួកគេនោះ។ មានប្រជាពលរដ្ឋម្នាក់បានប្រកាសថា "យើងត្រូវតែមានព្រះវិហារបរិសុទ្ធមួយនៅក្នុងសហគមន៍របស់យើង ។ យើងបានរង់ចាំយូរល្មមគ្រប់គ្រាន់ ហើយសំរាប់ពរជ័យនេះ"។ ហើយមានម្នាក់ផ្សេងទៀតបាននិយាយថា "បើយើងចង់ឱ្យមានព្រះវិហារបរិសុទ្ធមួយ នោះយើងត្រូវតែចាប់ផ្តើមសាងសង់ព្រះវិហារបរិសុទ្ធនោះឡើង"។ ហើយពួកគេក៏បានធ្វើដូច្នោះមែន។

ថ្មឯកត្រូវបានដាក់តម្កល់នៅថ្ងៃច័ន្ទ ទី 14 ខែ មេសា ឆ្នាំ 1879 ប្រមាណជា 30 ឆ្នាំបន្ទាប់ពីពួកគេបានមកដល់ជ្រលងភ្នំសាន់ប៉េតេ។ មានដំណើររឿងជាច្រើនដែលអាចត្រូវបានគេលើកឡើងពីភាពឧស្សាហ៍ព្យាយាមរបស់ក្រុមការងារ ដែលបានបញ្ចេញអស់ពីសមត្ថភាពរបស់ខ្លួននៅក្នុងការសាងសង់ព្រះវិហារបរិសុទ្ធដ៏ស្រស់ប្រណិតនេះ។ កាលពីប៉ុន្មានឆ្នាំកន្លងទៅ នៅឯការឧទ្ទិសឆ្លងឡើងវិញនៃព្រះវិហារមែនធៃ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានមានប្រសាសន៍ថា : "ខ្ញុំធ្លាប់បានឃើញអគារដ៏ប្រណិតជាច្រើនក្នុងពិភពលោក ប៉ុន្តែខ្ញុំមិនបានទទួលអារម្មណ៍ដូចគ្នានឹងការចូលមកកាន់ ព្រះវិហារបរិសុទ្ធដែលបានសាងសង់ដោយពួកអ្នកត្រួសត្រាយផ្លូវទាំងនេះឡើយ"។ គ្រួសាររបស់លោក ហ៊ិងគ្លី មានទំនាក់ទំនងជាពិសេសទៅនឹងព្រះវិហារបរិសុទ្ធមែនធៃនេះ--- ជីតារបស់ស៊ិស្ទើរ ម៉ាជ័ររី ហ៊ិងគ្លី បានបាត់បង់ជីវិតរបស់ខ្លួនដោយសារតែការរងរបួសមួយ ដែលបានកើតឡើងអំឡុងពេលនៃការសាងសង់ព្រះវិហារបរិសុទ្ធមែនធៃ ។

ដើម្បីយល់កាន់តែច្បាស់អំពីរបៀបដែលអតីតកាលអាចផ្តល់វិធីដ៏ប្រសើរមួយនៅក្នុងការប្រឈមមុខនឹងអនាគតកាល នោះខ្ញុំចង់ចែកចាយដំណើររឿងមួយដែលកើតមាននៅអំឡុងពេលនៃការសាងសង់ព្រះវិហារបរិសុទ្ធមែនធៃ ។ បន្ទាប់មក ខ្ញុំចង់ចែកចាយនូវអ្វីដែលដំណើររឿងនេះបានបង្រៀនខ្ញុំអំពីគោលការណ៍ពិតជាច្រើន។

មានជាងឈើដ៏ចំណានមួយចំនួនមកពីប្រទេសណរវេ បានមកដល់ទីក្រុងមែនធៃ ហើយក៏បានតាំងទីលំនៅនៅទីនោះ ហើយពួកគេបានទទួលការចាត់តាំងមួយដើម្បីសង់ដំបូលព្រះវិហារបរិសុទ្ធ។ ពួកគេពុំធ្លាប់សង់គ្រោងដំបូលពីមុនមកឡើយ ប៉ុន្តែពួកគេមានបទពិសោធន៍ជាអ្នកសង់សំពៅ។ ពួកគេមិនបានដឹងថាតើពួកគេនឹងត្រូវរៀបចំគ្រោងដំបូល ដោយរបៀបណានោះទេ។ បន្ទាប់មកពួកគេក៏បានមានគំនិតមួយថា : "ហេតុអ្វីបានជាយើងមិនសង់សំពៅតែម្តងទៅ? ដោយសារតែសំពៅដែលបានសង់ឡើងយ៉ាងប្រណិតនោះ គឺមានភាពមាំ និងសុវត្ថិភាព បើយើងត្រឡប់គ្រោងនោះ បញ្ច្រាស់មកវិញ នោះយើងនឹងមានដំបូលដ៏រឹងមាំមួយ"។ ពួកគេបានចាប់ផ្តើមរៀបផែនការសាងសង់សំពៅមួយ ហើយនៅពេលផែនការនោះបានបញ្ចប់សព្វគ្រប់ហើយ នោះពួកគេបានបង្វិលវាបញ្ច្រាស់វិញ ហើយវាក៏បានក្លាយ ទៅជាដំបូលនៃព្រះវិហារបរិសុទ្ធមែនធៃ ។

នៅក្នុងករណីនេះ ពួកគេបានប្រើមេរៀនពីបទពិសោធន៍កាលពីអតីតកាលរបស់ខ្លួន---ជាគោលការណ៍នៃការសង់សំពៅ---ដើម្បីជួយពួកគេប្រឈមមុខនឹងឧបសគ្គថ្មីមួយ។ ពួកគេក៏បានរកឃើញនូវហេតុផលដ៏សមរម្យផងដែរថា គោលការណ៍ដូចគ្នាដែលពួកគេធ្លាប់អនុវត្តទៅនឹងការសង់សំពៅលើផ្ទៃសមុទ្រមួយ ក៏អាចអនុវត្តចំពោះការសង់ដំបូលដ៏ រឹងមាំមួយបានដែរ។ ឧទាហរណ៍ គ្រោងទាំងនោះត្រូវការពារកុំឱ្យមានទឹកលិចដូចគ្នា។ សេចក្តីពិតជាមូលដ្ឋាននៃគ្រោងនោះ គឺវាពុំរងឥទ្ធិពលដោយសារតែទិសដៅរបស់វា

នោះទេ---ទោះបីជាវាផ្កាប់ ឬផ្ងារក៏ដោយ។ រឿងដ៏សំខាន់បំផុត គឺត្រូវមានចំណេះដឹងការងារមួយនៃគោលការណ៍មូលដ្ឋាន ដែលបានតំរូវឱ្យមាន ដើម្បីដាក់បញ្ឈរគ្រោងដែលសង់ចុងក្រោយគេបង្អស់។

នៅក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ បានបង្កប់នូវគោលការណ៍ និងសេចក្តីពិតដ៏នៅអស់កល្បជានិច្ច ដែលមានរយៈកាលយូរអង្វែងជាងគោលការណ៍នៃការសាងសង់សំពៅ និងដំបូលនោះទៅទៀត។ ក្នុងនាមជាសមាជិកសាសនាចក្រដ៏ពិត របស់ព្រះអម្ចាស់អ្នករាល់គ្នា ហើយនឹងរូបខ្ញុំមានសិទ្ធិទទួលបាន និងចំណេះដឹងពិសេសអំពីគោលការណ៍ និងសេចក្តីពិតដ៏នៅ អស់កល្បជានិច្ចទាំងនេះ ជាពិសេស នៅពេលយើងស្តាប់តាមព្រះវិញ្ញាណដើម្បីទទួលការដឹកនាំផ្ទាល់ខ្លួន និងសំរាប់គ្រួសារ ហើយស្តាប់តាមពាក្យសម្តីរបស់ព្យាការី នៅពេលលោកប្រកាសព្រះបន្ទូលនៃព្រះទៅកាន់សមាជិកសាសនាចក្រទាំងអស់នោះ។ អ្នករាល់គ្នា ហើយនឹងរូបខ្ញុំដឹងពីសារៈសំខាន់នៃគោលការណ៍ និងសេចក្តីពិតដ៏នៅអស់កល្បទាំងនេះនៅ ក្នុងជីវិតរបស់យើង។ ខ្ញុំជឿជាក់ថា ពួកអ្នកត្រួសត្រាយផ្លូវ សម័យមុនមិនអាចប្រឈមមុខនឹងអនាគតដ៏គ្រោះថ្នាក់ និងគ្មានភាពច្បាស់លាស់របស់ពួកគេបានឡើយ បើគ្មានគោលការណ៍ និងសេចក្តីពិតដ៏នៅអស់កល្បជានិច្ចទាំងនេះនោះ ហើយយើងក៏ដូចគ្នាផងដែរ។ គោលការណ៍ និងសេចក្តីពិតទាំងនេះគឺជាផ្លូវដ៏ពិត និងនៅអស់កល្បជានិច្ចតែមួយគត់ដើម្បី ប្រឈមមុខនឹងអនាគត ជាពិសេសនៅក្នុងគ្រាដ៏គ្រោះថ្នាក់ និងគ្មានភាពច្បាស់លាស់ដែល យើងកំពុងរស់នៅក្នុង ពេលនេះ។

ពួកអ្នកសង់សំពៅសញ្ជាតិណរវ៉េទាំងនេះ មានជំនាញដ៏សំខាន់ចំពោះមុខរបររបស់ពួកគេនៅក្នុងខ្លួន ដែលវាអាចបង្វែរពីការសង់សំពៅមកជាការសង់ព្រះវិហារបរិសុទ្ធវិញ។ តើអ្វីទៅដែលបណ្តាលឱ្យគំនិតរបស់ពួកគេមានការផ្លាស់ប្តូរ? គឺមានចម្លើយតែមួយគត់ដើម្បីពន្យល់ពីបញ្ហានេះ នោះគឺជាឆន្ទៈរបស់ពួកគេដើម្បីលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីក្លាយខ្លួនជាអ្នកសាងសង់នគរព្រះ។ ពួកគេត្រូវបានបង្រៀន និងបានទទួលយកគោលការណ៍ និងសេចក្តីពិតដ៏នៅអស់កល្បជានិច្ចនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ ពួកគេបានដឹងថា បេសកកម្មរបស់ខ្លួនពុំមែនគ្រាន់តែជួយសាងសង់ព្រះវិហារបរិសុទ្ធប៉ុណ្ណោះទេ ប៉ុន្តែដើម្បីបរិច្ចាគការសាងសង់នេះដល់មនុស្សដទៃទៀត តាមរយៈការចែកចាយចំណេះដឹងរបស់ខ្លួនអំពីដំណឹងល្អ។ នៅក្នុងកណ្ឌទី 50 នៃគោលលទ្ធិ និងសេចក្តីសញ្ញាបានចែងថា ៖ "អ្នកដែលផ្សាយ ហើយអ្នកដែលទទួល យល់គ្នាទៅវិញទៅមក ហើយទាំងពីរនាក់ត្រូវបាន ស្អាងឡើង ហើយត្រេកអរជាមួយគ្នា" (ខ. 22)។

នៅពេលយើងបានទទួលពរជ័យពិសេសចំពោះចំណេះដឹងស្តីអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និងលើកដាក់មកលើខ្លួនយើងនូវព្រះនាមរបស់ព្រះគ្រីស្ទ តាមរយៈការចូលទៅក្នុងទឹកនៃបុណ្យជ្រមុជទឹក នោះយើងក៏បានទទួលយកកាតព្វកិច្ច ដើម្បីចែកចាយដំណឹងល្អជាមួយនឹងមនុស្សដទៃផងដែរ។ ដើម្បីសំរេចបានទំនួលខុសត្រូវដ៏ពេញលេញរបស់យើងនៅក្នុងការចែកចាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ថ្មីៗនេះសាសនាចក្របានបង្វែរទិសដៅកម្មវិធីផ្សព្វផ្សាយសាសនា។ ប៉ុន្មានឆ្នាំមុន យើងបានលុបបំបាត់បេសកកម្មប្រចាំស្តេក ហើយបែរមកផ្តោតសំខាន់ចំពោះកិច្ចខិតខំរបស់យើងទៅលើអង្គការបេសកកម្មរបស់វួដវិញ។ តាមរយៈការបង្កើតផែនការបេសកកម្មរបស់វួដមួយ ដោយគ្រប់ក្រុមប្រឹក្សាប្រចាំវួដ ក្នុងសាសនាចក្រនេះ នោះអត្រានៃការរីកចំរើនបានកើនឡើងដែលពុំធ្លាប់មានពីមុនមកឡើយ។ ជោគជ័យនេះភាគច្រើនអាចសំរេចទៅបាន ដោយសារតែពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង បានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុម ប្រឹក្សាប្រចាំវួដ អ្នកដឹកនាំបេសកកម្មប្រចាំវួដ និងសមាជិកសាសនាចក្រ។

យើងបានរកឃើញថា កិច្ចការផ្សព្វផ្សាយសាសនាដែលពឹងផ្អែកទៅលើវួដ បានធ្វើឱ្យការចូលរួមចំណែករបស់សមាជិកនៅក្នុងការស្វែងរក និងការបង្រៀនដល់ពួកអ្នករៀនថ្មី គឺមានការកើនឡើង។ ជាញឹកញាប់ ពួកអ្នករៀនថ្មីត្រូវបានអញ្ជើញឱ្យទទួលយកមេរៀនរបស់អ្នកផ្សព្វផ្សាយសាសនានៅក្នុងគេហដ្ឋានរបស់សមាជិក។ សមាជិកនៅក្នុងវួដកាន់តែមានចិត្ត រីករាយនៅក្នុងការចែកចាយចំណេះដឹងដ៏មានតម្លៃរបស់ខ្លួនស្តីអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ នៅពេលពួកគេទទួលបទពិសោធន៍ដោយផ្ទាល់នូវពរជ័យដ៏ផ្អែមល្ហែមនៃការបំរើជាអ្នកផ្សព្វផ្សាយសាសនា និងនៅពេលពួកគេបានទទួលការ រំលឹកជាទៀងទាត់បន្ថែមទៀតពីសំណាក់ពួកអ្នកដឹកនាំក្នុងវួដរបស់ពួកគេ។ សមាជិកទាំងឡាយនឹងមានការយល់ដឹងដ៏ទូលំទូលាយថែមទៀត នៅពេលពួកគេពិចារណា និងអធិស្ឋានអំពីការចែកចាយដំណឹងល្អ ជាមួយនឹងមិត្តភក្តិ អ្នកជិតខាង និងសមាជិកគ្រួសារដែលមានជំនឿផ្សេងនោះ។

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានបង្រៀនថា : "យើងភាគច្រើនបានសម្លឹងមើលទៅកិច្ចការផ្សព្វផ្សាយថា គ្រាន់តែជាការដើរចែកកូនសៀវភៅអំពីដំណឹងល្អប៉ុណ្ណោះ។ មនុស្សគ្រប់គ្នាដែលស្គាល់ពីកិច្ចការនេះបានដឹងថា មានវិធីមួយ ទៀតដែលប្រសើរជាងនេះ។ វិធីនោះ គឺការធ្វើកិច្ចការនេះតាមរយៈសមាជិកសាសនាចក្រ។ នៅពេលណាមានសមាជិក ម្នាក់ណែនាំអ្នករៀនថ្មីម្នាក់ រំពេចនោះវានឹងមាននូវប្រព័ន្ធគាំទ្រមួយជាពុំខានឡើយ។ សមាជិកថ្លែងទីបន្ទាល់អំពី សេចក្តីពិតនៃកិច្ចការនេះ។ គាត់មានចិត្តអន្ទះសារចង់ឱ្យអ្នករៀនថ្មីដែលជាមិត្តភក្តិរបស់ខ្លួនមានសុភមង្គល។ គាត់នឹងមានចិត្តរីករាយ នៅពេលមិត្តម្នាក់នោះមានការរីកចំរើននៅក្នុងការរៀនសូត្រពីដំណឹងល្អ"។4

ពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងនឹងបន្តធ្វើការបង្រៀនដល់អ្នករៀនថ្មីភាគច្រើន ប៉ុន្តែសមាជិកទាំងឡាយត្រូវមានឱកាសច្រើនដើម្បីឆ្លើយនូវសំណួរ និងចែកចាយទីបន្ទាល់របស់ពួកគេ។ តាមរយៈការរៀបចំខ្លួនយើងបង្រៀនគោលការណ៍គ្រឹះនៃដំណឹងល្អ នោះយើងនឹងស្តាប់តាមពាក្យសម្តីទាំងស្រុងរបស់ព្យាការី។ ការរៀបចំខ្លួននឹងលុបបំបាត់នូវសេចក្តីភ័យខ្លាច ហើយវាក៏ធ្វើឱ្យមានភាពងាយស្រួល និងពង្រឹងនូវអ្វីដែលសមាជិកធ្វើនៅក្នុងការគាំទ្រដល់ ពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងនោះដែរ។ មានមេរៀនដ៏សាមញ្ញបំផុតចំនួនបី ដែលពួកអ្នកផ្សព្វផ្សាយសាសនា ពេញម៉ោងបង្រៀន រួមមាន---ការស្តារឡើងវិញ ផែនការសង្គ្រោះ និងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។ តើអ្នករាល់គ្នា ត្រូវបានរៀបចំខ្លួនដើម្បីធ្វើជាសាក្សី និងថ្លែងទីបន្ទាល់ចំពោះសេចក្តីពិតដ៏ពោរពេញនៃមេរៀនដ៏សាមញ្ញទាំងនេះបាន ប៉ុណាហើយ? សូមប្រើសៀវភៅណែនាំដ៏បំផុសគំនិតសំរាប់អ្នកផ្សព្វផ្សាយសាសនា "ប្រកាសដំណឹងល្អរបស់យើង" ដើម្បីសិក្សា និងរៀបចំខ្លួនរបស់អ្នកនៅក្នុងការធ្វើតួនាទីជាអ្នកគាំទ្រដល់ពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង នៅពេលពួកគេបង្រៀនពីការពិភាក្សាដំណឹងល្អដ៏សាមញ្ញទាំងនេះ។

សូមឱ្យយើងទាំងអស់គ្នារៀនពីមេរៀនដ៏សំខាន់ចំនួន ***ពីរ*** ដែលបានបង្រៀនដោយពួកវិស្វករធ្វើសំពៅមកពី ណាវូ ដែលបានសាងសង់ដំបូលនៃព្រះវិហារបរិសុទ្ធមែនថៃ ។ ទីមួយ គឺជាមេរៀននៃការប្រើគោលការណ៍ និងសេចក្តីពិត ពីអតីតកាល ដើម្បីជួយយើងឱ្យប្រឈមមុខនឹងអនាគត។ ទីពីរ យើងរៀនចេញពីបំណងប្រាថ្នារបស់ពួកគេនៅក្នុង ការចែកចាយនូវអ្វីដែលពួកគេដឹងជាមួយនឹងមនុស្សដទៃ ដើម្បីជួយកសាងនគរព្រះ។ មេរៀនទីពីរនេះ បើយើងរៀន សូត្រពីវាបានល្អ នោះយើងនឹងជួយមនុស្សដទៃទៀតជាច្រើន---រួមមានបងប្អូនប្រុសស្រីរបស់យើង និងបុត្រាបុត្រីផ្សេងទៀតនៃព្រះ---ឱ្យប្រឈមមុខនឹងអនាគតដែលមិនច្បាស់លាស់ជាមួយនឹង ការអះអាងដ៏នៅអស់កល្បជានិច្ចដូចដែលយើងមាន។ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ គឺជាការពិត។

ដំណឹងល្អនេះត្រូវបានស្ដារឡើងវិញ ដើម្បីប្រទានពរដល់ជីវិត របស់យើងនាថ្ងៃចុងក្រោយនេះ ។ ដំណឹងល្អនេះមានទូវរាល់សេចក្ដីពិត គោលការណ៍ និងពិធីបរិសុទ្ធដែលមាននៅក្នុង ផែនការនៃសុភមង្គលដ៏មហិមា របស់ព្រះវរបិតាសួគ៌ គឺជាផែនការមួយដើម្បីជួយយើងឱ្យត្រឡប់ទៅរស់នៅជាមួយនឹង ទ្រង់វិញដ៏នៅអស់កល្បជានិច្ច ។ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ គឺជាវិធីដ៏ទេវភាពរបស់ទ្រង់ដើម្បីជួយយើងឱ្យប្រឈមមុខ នឹងអនាគតដ៏រុងរឿងរបស់យើង នេះគឺជាទីបន្ទាល់របស់ខ្ញុំទៅកាន់អ្នករាល់គ្នា ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. បានដកស្រង់ដោយ George Will "One Man's America", *Cato Policy Report* ខែ កញ្ញា---តុលា ឆ្នាំ 2008 ទំព័រ 11 ។

2. បានដកស្រង់នៅក្នុង Wilford Woodruff "Celebration of Pioneers' Day" *The Utah Pioneers* (ឆ្នាំ 1880) ទំព័រ 23 ។

3. បានដកស្រង់នៅក្នុង "Manti Temple Rededicated" *Ensign* ខែ សីហា ឆ្នាំ 1985 ទំព័រ 73 ។

4. Gordon B. Hinckley "Find the Lambs, Feed the Sheep" *Liahona* ខែ តុលា ឆ្នាំ 1999 ទំព័រ 119 ។